# របៀបឲ្យគេរាប់សន្លឹកឆ្នោតរបស់លោកអ្នក

នៅថ្ងៃបោះឆ្នោត លោកអ្នកនឹងបានទទួលសន្លឹកឆ្នោតពីរសន្លឹក៖ សន្លឹកឆ្នោត**ពណ៌បៃតង** គឺសម្រាប់សភាតំណាងរាស្ត្រ ហើយសន្លឹកឆ្នោត**ពណ៌ស** គឺសម្រាប់ព្រឹទ្ធសភា។

## សភាតំណាងរាស្ត្រ

នៅលើ**សន្លឹកឆ្នោតពណ៌បៃតង** លោកអ្នកនឹងត្រូវការដាក់លេខ ‘1’ នៅក្នុងប្រអប់ក្បែរបេក្ខជនដែលជាជម្រើសទីមួយរបស់លោកអ្នក, ដាក់លេខ ‘2’ នៅក្នុងប្រអប់ក្បែរជម្រើសទីពីររបស់លោកអ្នក និងជាបន្តបន្ទាប់ រហូតទាល់តែលោកអ្នកបានដាក់លេខរៀងរាល់ប្រអប់។

លោកអ្នកត្រូវដាក់លេខ**រៀងរាល់ប្រអប់** ដើម្បីឲ្យគេរាប់សន្លឹកឆ្នោតរបស់លោកអ្នក។




សន្លឹកឆ្នោតគំរូ

## ព្រឹទ្ធសភា

នៅលើ**សន្លឹកឆ្នោតពណ៌ស** លោកអ្នកអាចជ្រើសរើសបោះឆ្នោតក្នុងវិធីមួយណាក៏បាន គឺនៅលើខ្សែបន្ទាត់ ឬនៅក្រោមខ្សែបន្ទាត់។




### មួយណាក៏បាន នៅលើខ្សែបន្ទាត់

ប្រសិនបើលោកអ្នកបោះឆ្នោតនៅលើខ្សែបន្ទាត់ លោកអ្នកត្រូវដាក់លេខ**ឲ្យបានយ៉ាងតិច 6 ប្រអប់** ចាប់ពី 1 ទៅ 6។

សូមដាក់លេខ ‘1’ នៅក្នុងប្រអប់សម្រាប់គណបក្ស ឬក្រុមដែលជាជម្រើសទីមួយរបស់លោកអ្នក, ដាក់លេខ ‘2’ នៅក្នុងប្រអប់សម្រាប់គណបក្ស ឬក្រុមដែលជាជម្រើសទីពីររបស់លោកអ្នក និងជាបន្តបន្ទាប់ រហូតទាល់តែលោកអ្នកបានដាក់លេខយ៉ាងតិចប្រាំមួយប្រអប់។ លោកអ្នកអាចបន្តដាក់លេខនៅក្នុងប្រអប់យ៉ាងច្រើននៅលើខ្សែបន្ទាត់ តាមដែលលោកអ្នកប្រាថ្នា។




### ឬ នៅក្រោមខ្សែបន្ទាត់

ប្រសិនបើលោកអ្នកបោះឆ្នោតនៅក្រោមខ្សែបន្ទាត់ លោកអ្នកត្រូវដាក់លេខ**ឲ្យបានយ៉ាងតិច 12 ប្រអប់** ចាប់ពី 1 ទៅ 12។

សូមដាក់លេខ ‘1’ នៅក្នុងប្រអប់ក្បែរបេក្ខជនដែលជាជម្រើសទីមួយរបស់លោកអ្នក, ដាក់លេខ ‘2’ នៅក្នុងប្រអប់ក្បែរជម្រើសទីពីររបស់លោកអ្នក និងជាបន្តបន្ទាប់ រហូតទាល់តែលោកអ្នកបានដាក់លេខយ៉ាងតិច 12 ប្រអប់។ លោកអ្នកអាចបន្តដាក់លេខនៅក្នុងប្រអប់យ៉ាងច្រើននៅក្រោមខ្សែបន្ទាត់ តាមដែលលោកអ្នកប្រាថ្នា។

សន្លឹកឆ្នោតគំរូ

**សូមកុំខ្វល់ព្រួយអ្វីឡើយប្រសិនបើលោកអ្នកបំពេញខុស។ លោកអ្នកអាចស្នើសុំសន្លឹកឆ្នោតមួយផ្សេងទៀត ហើយចាប់ផ្តើមបំពេញម្តងទៀត។**

EM274 18_0989